San Diego City Schools
លិខិតពត៌មាន
រដូវស្លឹកឈើលាស់ឆ្នាំ ២០០៤

# ពត៌មានចំនួន ដប់ពីរប្រការ សំរាប់លោកគ្រូ-អ្នកគ្រូអាចបញ្ឈប់អំពើឃោរឃៅនៅតាមសាលារៀន

ទីប្រឹក្សាការពារឧក្រិដ្ឋកម្មជាតិមានបំណងចង់ជួយបំបាត់អំពើឃោរឃៅនៅតាមសាលារៀនដែលមានការចាប់ផ្តើមនឹងគម្រោងបញ្ជីគំនិតនេះ។ យោបល់-គំនិតមួយចំនួនតម្រូវអោយមានតែការប្រតិបត្តិផ្ទាល់, មួយចំនួនទៀតតម្រូវឲ្យមានការប្រឹងប្រែង។ មួយចំនួនទៀតត្រូវតែលើកដោះស្រាយភ្លាមៗ។ មួយចំនួនទៀតត្រូវតែលើកឡើងនូវបញ្ហាដែលកើតឡើងដោយសារអំពើឃោរឃៅ។ចូរពិចារណាថា នេះជាកិច្ចការដែលត្រូវប្រតិបត្តិ - មានវិធីច្រើនប្រការដែលអាចធ្វើការដោះស្រាយបាន។

១. រាយការណ៍ទៅចាងហ្វាងប្រចាំសាលារៀនឲ្យបានឆាប់រហ័សនូវអំពើគម្រាមកំហែង, ឃើញសញ្ញាថាមានអាវុធ, សកម្មភាពជនអ្នកលេង, ឬលក្ខណៈផ្សេងៗដែលទាក់ទងនឹងអំពើឃោរឃៅ។

២. ចូររៀបចំឲ្យមានវិន័យផ្នែកអាកប្បកិរិយាល្អនៅតាមបន្ទប់រៀន។បដិសេធមិនឲ្យប្រើអំពើឃោរឃៅនៅជាដាច់ខាត។ ពិគ្រោះមួយជាសិស្សឲ្យជួយរៀបចំវិន័យដាក់ទណ្ឌកម្ម និងបង្កើតវិន័យឲ្យបានរឹងមាំ។

៣. ចូរអញ្ជើញមាតាបិតាមកពិគ្រោះអំពី ការសិក្សារបស់កូនព្រមទាំងការចាប់អារម្មណ៍របស់គាត់។ចូរផ្ញើលិខិតអញ្ជើញមាតាបិតាបិតាសិស្សមកចូលរួម ពេលកូនរបស់គាត់ទទួលសញ្ញាប័ត្រអ្វីមួយ។

៤. ចូររៀននូវរបៀបចងចាំសិស្សដែលមានសញ្ញាប្រព្រឹត្តអំពើឃោរឃៅ ព្រមទាំងប្រភពពត៌មានដើម្បីជួយដល់សិស្ស។

៥. ចូរលើកទឹកចិត្ត និងធ្វើការធានាបង្កើតកម្មវិធីប្រឆាំងនឹងអំពើឃោរឃៅសំរាប់សិស្ស, បង្កើតកម្មវិធីអប់រំសិស្ស, បង្កើតឲ្យមានតុលាការដោះស្រាយយុវជន, និងធ្វើការសម្រុះសម្រួល និងណែនាំ ព្រមទាំងហ្វឹកហ្វឺនដល់សិស្សផងដែរ។

៦. ចូលរួមបំរើជាមួយក្រុម ឬគណៈកម្មការដើម្បីបង្កើតគម្រោងសន្តិសុខសាលារៀន រួមទាំងរបៀបដោះស្រាយបញ្ហាទូទៅដល់លោកគ្រូ-អ្នកគ្រូនិងបុគ្គលិកសាលារៀន ពេលមានភាពអាសន្នអ្វីមួយ។

៧. ពង្រឹងច្បាប់ដើម្បីបន្ថយអំពើឃោរឃៅនៅតាមសាលារៀន។ ចូរធ្វើការចាត់ចែងឲ្យមានរបៀបរៀបរយល្អនៅក្នុងបន្ទប់រៀនសិស្ស និងបរិវេណរបស់សាលារៀន។

៨. ចូរណែនាំសិស្សមិនត្រូវជេរគ្នា, ចំអន់គ្នាលេង។ លើកទឹកចិត្តសិស្សឲ្យធ្វើធ្វើការគោរពគ្នា។ ណែនាំសិស្សឲ្យចេះចូលរួមបង្កើតខ្នាតគំរូផ្នែកអាកប្បកិរិយាឲ្យបានល្អ។

៩. ចូរធ្វើការបង្រៀនដោយមានចិត្តសប្បាយរីករាយជាមួយសិស្ស។ សិស្សមានការជាប់ទាក់ទងនឹងរបៀបសិក្សាដែលមានការប្រកួតប្រជែងគ្នា ហើយលើកទឹកចិត្តដែលធ្វើឲ្យសិស្សមិនសូវមានបញ្ហា។

១០. ធ្វើការសិក្សា និងបង្រៀននូវជំនាញការដោះស្រាយ និងជំនាញការចាត់ចែង។ ចូរជួយដល់សិស្សអនុវត្តន៍អោយបានរាល់ថ្ងៃ។ ចូរពិគ្រោះកិច្ចការទាំងនេះដើម្បីឲ្យមានការបញ្ចូលជាមួយការបង្រៀនរបស់អ្នក។

១១. ចូលរួមសហការណ៍ពិគ្រោះអំពី អំពើឃោរឃៅ និងរបៀបការពារ ពេលអ្នកធ្វើការបង្រៀនមេរៀនអ្វីមួយ។

១២. ចូរលើកទឹកចិត្តសិស្សធ្វើសេចក្តីរាយការណ៍នូវអំពើឃោរឃៅ ឬសកម្មភាពនៃអំពើឧក្រិដ្ឋកម្មដែលសិស្សមានការសង្ស័យ ហើយមានអារម្មណ៍មិនស្រួល។

## សង្ខេប

- ធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅចាងហ្វាង ឬអគ្គនាយកប្រចាំសាលារៀននូវអំពើឃោរឃៅ ឬអាកប្បកិរិយាដែលគួរឲ្យសង្ស័យ
- បដិសេធមិនឲ្យប្រើអំពើឃោរឃៅ
- អញ្ជើញមាតាបិតាមកចូលរួមពិគ្រោះអំពី ការសិក្សារបស់សិស្ស
- ចូររៀនចងចាំនូវសញ្ញាអំពើឃោរឃៅរបស់សិស្សដែលបង្ហាញ
- ចូរលើកទឹកចិត្ត និងបង្កើតកម្មវិធីប្រឆាំងនឹងអំពើឃោរឃៅ
- ចូរបំរើនៅតាមក្រុមដើម្បីបង្កើតគម្រោងការសាលារៀនឲ្យសិស្សមានសន្តិសុខដើម្បីជួយដល់បុគ្គលិកប្រតិបត្តិ ពេលមានភាពអាសន្ន
- ចូរគ្រប់គ្រងនៅតាមបរិវេណសាលារៀន និងនៅតាមបន្ទប់រៀន។
- ចូរលើកទឹកចិត្តសិស្សឲ្យបង្ហាញការគោរព
- ព្យាយាមបង្រៀនដោយយកចិត្តទុកដាក់
- ចូរធ្វើការសិក្សា និងបង្រៀនសិស្សឲ្យចេះដោះស្រាយ និងមានជំនាញចាត់ចែងភាពកំហឹង
- លើកទឹកចិត្តសិស្សពិគ្រោះអំពី របៀបការពារអំពើឃោរឃៅ
- លើកទឹកចិត្តសិស្សធ្វើសេចក្តីរាយការណ៍អំពីអំពើឧក្រិដ្ឋកម្ម, សកម្មភាពនៃអំពើឃោរឃៅ ឬស្ថានការមិនធម្មតាជាបន្ទាន់

អត្ថបទនេះផ្តល់ជូន និងបោះពុម្ពដែលមានការអនុញ្ញាតិចេញពី ទីប្រឹក្សាការពារអំពើឧក្រិដ្ឋកម្មជាតិ ©.
ពត៌មានបន្ថែមស្តីអំពី ទីប្រឹក្សាការពារអំពើឧក្រិដ្ឋកម្មជាតិ ចូរបើប្រព័ន្ធ website at (www.ncpc.org).
ពត៌មានបន្ថែមស្តីអំពី ការបំរើចេញពីក្រសួងប៉ូលិសប្រចាំ សាន់ឌិអេហ្គោ ចូរបើកប្រព័ន្ធ website: (http:pro031.sandi.net/policeservices/).
បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងពត៌មាន: ក្រសួងប៉ូលិសៈ (៦១៩) ៧២៥-៧០០០ អគ្គិភ័យ (៦១៩) ២៦១-៧៦៣៨ ការទាក់ទង ពេលមានភាពអាសន្ន
ការតម្រូវតាមសាធារណៈ (៦១៩) ៧២៥-៥៥៧៨ www.sandi.net

ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌិអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៨៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្ត្រ។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាំគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

* បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌិអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ *